Who: Mr TOY HONG
What ask for Reporter to take news at examination for law maker
Where at law faculty
When 14-16/11/96

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

****

# គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

រាជធានីភ្នំពេញ , ថ្ងៃទី ៤ វិច្ឆិកា ១៩៩៦

លេខ : ៣៤០/គ.ម/៩៦

**សូមគោរពជូន**

លោកនាយក កាសែត **Phnom - Penh Post**

សូមជ្រាប ។

កម្មវត្ថុ : សំណើសុំជួយផ្តល់អ្នកយកពត៌មាន ។

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយស សូមលោកចាងហ្វាងមេត្តាជួយផ្តល់សហការី ចូលរួមយកពត៌មាន ក្នុងសម័យប្រឡងជ្រើសរើស សិស្សមេធាវីជំនាន់ទី ៣ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃ ព្រហស្បត្តិ៍ ទី ១៤ និងថ្ងៃ សៅរ៍ ទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ វេលាម៉ោង ៧.៣០ នាទីព្រឹក នៅមហាវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ភ្នំពេញ ។

សូមលោក ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

\- គណៈមេធាវី
នៃព្រះរាជាណាចក្រកម្ពុជា
នាយករដ្ឋបាល

[illegible]

ជូនភ្ជាប់ជាមួយនូវ :
-សេចក្តីប្រកាសជូនដំណឹង

ទីស្នាក់ការ នៅផ្ទះលេខ ផ្លូវសម្តេចចក្រីប៉ុន ( អតីតផ្លូវលេខ ២០៨ ) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ លេខ : ( 015 ) 919 166 , Tel / Fax : ( 855 ) 23.723.984 .

who: Mr SAY BORY
what: about ~~test~~ of exam
where: at Law faculty
when: 14-16/11/96 at 7h 30 am

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

8888888888888888888888

# គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

លេខ : ៣៣០/គ.ម/៩៦

## សេចក្តីប្រកាសជូនដំណឹង

◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆◆

ដើម្បីឱ្យមានយុត្តិធម៌ និងតម្លាភាពពិតប្រាកដ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានសំរេចរៀបចំការប្រកួតប្រជែងប្រឡងចូលរៀន ជាសិស្សមេធាវីជំនាន់ទី ៣ នៅថ្ងៃទី ១៤ វិច្ឆិកា ១៩៩៦ ចាប់ពីម៉ោង ៧.៣០ នៅក្នុងមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ភ្នំពេញ ដោយមានធ្វើតែវិញ្ញាសារសរសេរ របៀប QCM គឺឱ្យឆ្លើយតែត្រឹមថា ខុស ឬ ត្រូវ ប៉ុណ្ណោះ និងដោយមានវិធានការដូចតទៅ គឺ :

១- មានសំនួរទាំងអស់ ១៦០ សំនួរ ដែលគ្រប់ដណ្តប់ទៅលើកម្មវិធីទាំងអស់ នៃមុខវិជ្ជា ដែលត្រូវប្រឡង គឺ នីតិរដ្ឋប្បវេណី , នីតិវិធី នៃនីតិរដ្ឋប្បវេណី , នីតិព្រហ្មទណ្ឌ , នីតិវិធី នៃនីតិព្រហ្មទណ្ឌ , ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី , ពាណិជ្ជកិច្ច និងបញ្ជីពាណិជ្ជកម្ម ។

២- សំនួរនីមួយ ៗ សរសេរក្នុងក្រដាសមួយសន្លឹកដូចជាសន្លឹកឆ្នោត ១ សំរាប់ឱ្យចាប់រើសយក មកធ្វើជាសំនួរ នៃវិញ្ញាសាប្រឡង ។ ត្រូវចាប់ទាញរើសយកតែ ៤០ សន្លឹក គឺថា តែ ៤០ សំនួរ ក្នុងចំណោម ១៦០ សំនួរ នៅថ្ងៃទី ១៤ វិច្ឆិកា នោះតែម្តង នៅចំពោះមុខ បេក្ខជនដែលមានក្នុងបន្ទប់ប្រឡងទី ១ ចំពោះមុខអ្នកកាសែតខ្មែរនិងបរទេស ចំពោះ មុខទូរទស្សន៍ វិទ្យុជាតិ ចំពោះមុខតំណាង ABA ( សមាគមមេធាវីអាមេរិកាំង ) តំណាង USF ( សាកលវិទ្យាល័យ San Francisco ) តំណាងបារាំង ( លោកស្រី ចៅក្រម Marie Hirigoyen ) តំណាង USAID និងតំណាង NGO ខាងវិស័យច្បាប់ និងវិស័យសិទ្ធិមនុស្ស ។

សំនួរដែលចាប់បានទាំង ៤០ នោះ ត្រូវយកមកសូត្រឱ្យបេក្ខជនកត់ក្នុងក្រដាស ប្រឡង ហើយនឹងមានកត់បន្តបន្ទាប់នៅលើក្តារខៀន ម្តងមួយ ៗ ថែមទៀត ។



ទីស្នាក់ការ នៅផ្ទះលេខ ផ្លូវសម្តេចចក្រីប៊ុន ( អតីតផ្លូវលេខ ២០៨ ) សង្កាត់បឹងរាង ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ លេខ : ( 015 ) 919 166 , Tel / Fax : ( 855 ) 23.723.984 .